អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះបញ្ចប់សវនាការរយៈពេលបីថ្ងៃនៅក្នុងសំណុំរឿង ០០៣

នៅថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបញ្ចប់សវនាការរយៈពេលបីថ្ងៃនៅក្នុងសំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត។ សហព្រះរាជអាជ្ញាអន្តរជាតិ សហព្រះរាជអាជ្ញារងជាតិ និង សហមេធាវីការពារក្តីជាតិ-អន្តរជាតិ បានបង្ហាញទឡ្ហីករណ៍របស់ខ្លួននៅក្នុងសំណុំរឿងនេះ។ អង្គបុរេជំនុំជម្រះបានសម្រេចតាមការស្នើសុំរបស់ មាស មុត ដោយមាស មុត បានផ្តល់ជូនអង្គបុរេជំនុំជម្រះនូវលិខិតបញ្ជាក់សុខភាពដែលបញ្ជាក់ថាដោយសារមូលហេតុវ័យចំណាស់ និងសុខភាពខ្សោយ គាត់មិនមានកាយសម្បទាគ្រាប់គ្រាន់នឹងចូលរួមសវនាការឡើយ។ គាត់មានសហមេធាវីតំណាងគាត់នៅក្នុងសវនាការនេះ។

អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាជាតិ និង សហមេធាវីការពារក្តីអោយ មាស មុត នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ និង នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ជាបន្តបន្ទាប់ ប្រឆាំងនឹងដីកាដំណោះស្រាយដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៣ និងបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ មាស មុត ដែលចេញដោយសហចៅក្រមស៊ើបអង្កេតជាតិនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៣។

របាយការណ៍សំណុំរឿងមួយដែលបង្ហាញអំពីអង្គហេតុនិងប្រវត្តិនីតិវិធីពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៣ ព្រមទាំងសេចក្តីលម្អិតនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ត្រូវបានចេញក្នុងនាមអង្គបុរេជំនុំជម្រះទាំងមូល។ សំណៅជាសាធារណៈដោយមានការកោសលុបនៃរបាយការណ៍នេះអាចរកមើលបានតាមរយៈគេហទំព័រ៖

https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D266_15_KH-Redacted.PDF

អង្គបុរេជំនុំជម្រះនឹងធ្វើការសម្រេចថាតើ មាស មុត ត្រូវតាមលក្ខខណ្ឌតម្រូវនៃយុត្តាធិការរបស់តុលាការដែរឬអត់ និងថាតើមានបទចោទគ្រប់គ្រាន់ដើម្បីបញ្ជូនគាត់ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មតាមការចោទប្រកាន់ ឬ ការ

ចោទប្រកាន់ប្រឆាំងនឹងគាត់នឹងត្រូវលើកលែងចោទ។ សម្រាប់ពេលឥឡូវនេះ អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណា ដើម្បីចេញសាលដីកាសម្រេច។ សាលដីកាសម្រេចនេះគឺជាសាលដីកាស្ថាពរ មិនមានបណ្តឹងឧទ្ធរណ៍បន្ថែមទៀតទេ។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*


លោក នេត្រ ភក្ត្រា

ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ

ទូរស័ព្ទចល័ត+៨៥៥(0)១២៤៨៨១៥៦

ទូរស័ព្ទលើតុ: +៨៥៥(0)២៣៨៦១៥៦៤

អ៊ីមែល: neth.pheaktra@eccc.gov.kh